គណៈកម្មការមូលបត្រកម្ពុជា

លេខ:....០០៥/១២....គ.ម.ក/ប្រ.ក.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
# ស្តីពី
# ការបង្ហាញព័ត៌មានសាជីវកម្ម

* * * * *

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់ពីលក្ខខណ្ឌតម្រូវ យន្តការ នីតិវិធី និងកាតព្វកិច្ចរបស់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ(សរសេរកាត់ថា បុគ្គលបោះផ្សាយ) និងបុគ្គលពាក់ព័ន្ធក្នុងការបង្ហាញព័ត៌មានសាជីវកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលបោះផ្សាយ និងបុគ្គលពាក់ព័ន្ធក្នុងការផ្តល់របាយការណ៍ និងព័ត៌មានដែលត្រូវបង្ហាញក្រោយការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងគោលបំណងធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការបង្ហាញព័ត៌មានសាជីវកម្ម ដើម្បីការពារផលប្រយោជន៍របស់វិនិយោគិន និងសាធារណជន។

### ប្រការ ៣.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ការផ្តល់ព័ត៌មានសាជីវកម្ម សំដៅដល់ឯកសារផ្តល់ព័ត៌មានជាប្រចាំដែលប្រើនៅក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-ការផ្ទេរទ្រព្យសកម្ម (Asset Transfer) សំដៅដល់ការផ្លាស់ប្តូរភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្ម។

៣-ការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិ (Stock Buy-Back and Cancellation) សំដៅដល់ការទិញមកវិញនូវមូលបត្រកម្មសិទ្ធិដោយបុគ្គលបោះផ្សាយ ហើយលុបចោលមូលបត្រកម្មសិទ្ធិនោះ ពីចំនួនមូលបត្រកម្មសិទ្ធិសរុបរបស់បុគ្គលបោះផ្សាយ។

៤-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក (Merger & Acquisition) សំដៅដល់យុទ្ធសាស្ត្ររបស់បុគ្គលបោះផ្សាយក្នុងការទិញ លក់ និងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្នុងគោលបំណងសម្រេចបានកំណើនឆាប់រហ័ស ឬក្នុងគោលបំណងជាក់លាក់ផ្សេងទៀត។

៥-ការទទួលកាន់កាប់បន្ត (Takeover) សំដៅដល់ការសម្រេចបាននូវការត្រួតត្រាតាមរយៈការទិញធុរកិច្ច ឬទ្រព្យសកម្មរបស់បុគ្គលណាមួយ។

៦-ឌីប៉ូស៊ីតធើរីរីស៊ីប ឬលិខិតបញ្ជាក់តំណាងមូលបត្រ (Depositary Receipts) សំដៅដល់ឧបករណ៍ដេរីវេទីវតំណាងឱ្យមូលបត្ររបស់បុគ្គលបោះផ្សាយ ដែលត្រូវបានដាក់ឱ្យជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតបរទេស។

៧-សំណើទិញផែនខ័រ (Tender Offer) សំដៅដល់សំណើសុំទិញដែលបើកចំហជាសាធារណៈដើម្បីទិញមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងចរាចរនៅលើទីផ្សារ ឬសំណើសុំទិញដែលមានគោលដៅត្រួតត្រាលើបុគ្គលបោះផ្សាយណាមួយ។

៨-មូលបត្របំណុលបរិវត្ត (Convertible Bond) សំដៅដល់មូលបត្របំណុលដែលអាចប្តូរទៅជាមូលបត្រកម្មសិទ្ធិ ឬជាប្រភេទផ្សេងទៀតនៃទ្រព្យសកម្មរបស់បុគ្គលបោះផ្សាយ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៩-មូលបត្របំណុលមានការធានា (Bond With Warrants) សំដៅដល់មូលបត្របំណុលដែលអនុញ្ញាតឱ្យអ្នកកាន់កាប់មូលបត្របំណុលនោះ មានសិទ្ធិក្នុងការទិញមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយក្នុងតម្លៃ និងតាមកាលបរិច្ឆេទ ដែលបានកំណត់ជាក់លាក់។

១០-ម៉ោងជួញដូរ សំដៅដល់ម៉ោងបើកឱ្យមានការជួញដូរនៅលើទីផ្សារមូលបត្រប្រតិស្រុតស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្រ ដែលទទួលបានការអនុម័តពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

១១-ម៉ោងធ្វើការ សំដៅដល់ម៉ោងធ្វើការរបស់ **គ.ម.ក.** ឬរបស់ទីផ្សារមូលបត្រប្រតិស្រុត។

១២-ព័ត៌មានទាន់ពេល (Timely Disclosure) សំដៅដល់ព័ត៌មានទាំងឡាយណា ដែលអាចមានផលប៉ះពាល់ដល់ថ្លៃ ឬការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ ហើយនៅពេលដែលព័ត៌មានទាំងនោះកើតមានឡើង បុគ្គលបោះផ្សាយត្រូវធ្វើការបង្ហាញព័ត៌មាននោះភ្លាម។

១៣-ព័ត៌មានពិសេស (Special Disclosure) សំដៅដល់ព័ត៌មានដូចជា ការទិញមកវិញនិងលុបចោលមូលបត្រកម្មសិទ្ធិ សំណើទិញផែនខ័រ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក និងការទទួលកាន់កាប់បន្ត។

១៤-ព័ត៌មានតាមការស្នើសុំ (Requested Disclosure) សំដៅដល់ព័ត៌មានទាំងឡាយណាដែល **គ.ម.ក.** តម្រូវឱ្យបុគ្គលបោះផ្សាយធ្វើការបង្ហាញ។

១៥-របាយការណ៍សាមាយិក (Periodic Report) សំដៅដល់របាយការណ៍ដែលត្រូវបានរៀបចំសម្រាប់រយៈពេលនៃការរាយការណ៍ជាក់លាក់ណាមួយ រួមមាន របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

## ជំពូកទី ២
## ប្រភេទ និងលក្ខខណ្ឌនៃការបង្ហាញព័ត៌មានសាជីវកម្ម

### ប្រការ ៤.- ព័ត៌មានសាជីវកម្មដែលត្រូវបង្ហាញ

ព័ត៌មានសាជីវកម្មដែលបុគ្គលបោះផ្សាយ ត្រូវបង្ហាញរួមមាន ព័ត៌មានទាន់ពេល របាយការណ៍សាមាយិក ព័ត៌មានពិសេស និងព័ត៌មានតាមការស្នើសុំ។

### ប្រការ ៥.- ព័ត៌មានដែលត្រូវបង្ហាញទាន់ពេល

បុគ្គលបោះផ្សាយ ត្រូវផ្ដល់ព័ត៌មានជូន **គ.ម.ក** នូវព្រឹត្តិការណ៍ដែលអាចកើតមាន ដូចខាងក្រោម÷

១-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកក្នុងការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដោយលម្អិតអំពី ទីកន្លែង ពេលវេលា របៀបវារៈប្រជុំ និងលក្ខខណ្ឌសម្រាប់ការចូលរួម និងអ្នកចូលរួម។

២-សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិកពាក់ព័ន្ធនឹងការផ្លាស់ប្តូរគោលការណ៍ណែនាំធុរកិច្ច ឬវិសាលភាពធុរកិច្ច ការផ្លាស់ប្តូរគោលដៅ ឬលក្ខណៈនៃធុរកិច្ច ការផ្លាស់ប្តូរឈ្មោះបុគ្គលបោះ-ផ្សាយ ឬការសម្រេចចិត្តដទៃទៀតដែលអាចមានផលប៉ះពាល់ខ្លាំងលើការគ្រប់គ្រងធុរកិច្ច ឬទ្រព្យរបស់បុគ្គលបោះផ្សាយ។

៣-ការប្រែប្រួលណាមួយនៃក្រុមប្រឹក្សាភិបាល ឬការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់។

៤-ករណីមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និង/ឬ ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់។

៥-ករណីអភិបាលឯករាជ្យ ឬសវនករឯករាជ្យ រួមទាំងសមាជិកគណៈកម្មាធិការសវនកម្មបានសុំលាលែងពីតំណែងក្រៅពីហេតុផលនៃការបញ្ចប់អាណត្តិរបស់ខ្លួន។

៦-ករណីបុគ្គលបោះផ្សាយមានប្រកាសនីយបត្រតក្កកម្មថ្មី (New Patent) ឬកម្មសិទ្ធិបញ្ញានៃបច្ចេកវិទ្យាថ្មី ឬគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលអាចមានផលប៉ះពាល់ខ្លាំងលើផលិតកម្ម និងសកម្មភាពធុរកិច្ច។

៧-ការចាប់ផ្តើម ឬការបញ្ឈប់ ធ្វើជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនហូលឌីងណាមួយ ឬការទទួលបានក្រុមហ៊ុនណាមួយមកធ្វើជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ។

៨-ការសម្រេចចិត្តបង្កើន ឬបន្ថយដើមទុន ឬការសម្រេចក្នុងការបំបែក ឬបង្រួមមូលបត្រកម្មសិទ្ធិ។

៩-ការសម្រេចចិត្តបើកភាគលាភជាសាច់ប្រាក់ ឬជាមូលបត្រកម្មសិទ្ធិ។

១០-ការសម្រេចចិត្តផ្តល់ឱ្យ ឬលុបចោលសិទ្ធិទិញមូលបត្រកម្មសិទ្ធិ (Stock Options)។

១១- ការសម្រេចចិត្តបោះផ្សាយមូលបត្របំណុលបរិវត្ត (Convertible Bonds) មូលបត្របំណុលមានការធានា (Bond with Warrants) ឬឌីប៉ូស៊ីតធើរីរិស៊ីប ឬលិខិតបញ្ជាក់តំណាងមូលបត្រ (Depositary Receipts)។

១២-ករណីមានការសម្រេចចិត្តចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតបរទេស។ ករណីមូលបត្ររបស់បុគ្គលបោះផ្សាយត្រូវបានព្យួរ ឬត្រូវបានដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុតបរទេស។

១៣-ការសម្រេចចិត្តដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ។

១៤-ការសម្រេចចិត្តទិញមកវិញនិងការលុបចោលនូវមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ។

១៥-ករណីលិខិតសងតាមបញ្ជា ឬមូលប្បទានបត្រ ត្រូវបានបដិសេធដោយធនាគារ ឬករណីប្រតិបត្តិការណាមួយជាមួយធនាគារត្រូវបានព្យួរ ឬហាមឃាត់។

១៦- ករណីមានហេតុផលដែលអាចនឹងបណ្តាលឱ្យមានការរំលាយក្រុមហ៊ុន។

១៧-ករណីមានការទាមទារពីធនាគារដែលជាឥណទាយកធំជាងគេ ដែលអាចនឹងបណ្តាលឱ្យមានការអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការរៀបចំក្រុមហ៊ុនឡើងវិញ ការជម្រះបញ្ជី ការរំលាយក្រុមហ៊ុន ឬការដាក់ឱ្យក្ស័យធន។

១៨-ការសម្រេចលើការចាប់ផ្តើម ការផ្អាក ឬការបញ្ចប់ការគ្រប់គ្រង ឬការត្រួតពិនិត្យរួមគ្នាដោយធនាគារដែលជាឥណទាយកធំជាងគេ។

១៩-ករណីមានការដាក់ ការចាត់ការ ឬការចេញសេចក្តីសម្រេចដោយតុលាការមានសមត្ថកិច្ចលើបណ្តឹងណាមួយដែលអាចមានផលប៉ះពាល់លើការគ្រប់គ្រង ឬធុរកិច្ច ឬទ្រព្យដែលជាផ្នែកមួយនៃអចលកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ។

២០-ករណីមានការចោទប្រកាន់ពីការបំពានលើស្តង់ដារគណនេយ្យដែលបានដាក់ឱ្យប្រើប្រាស់ជាធរមាននៅកម្ពុជា ឬករណីមានការបញ្ជូនទៅព្រះរាជអាជ្ញាដើម្បីធ្វើការស៊ើបអង្កេត។

២១-ករណីមានការបញ្ជាក់ថាមាន ឬមានការសង្ស័យថាមាន ការអនុវត្តមិនត្រឹមត្រូវ ឬការតែងបន្ថែមដោយអភិបាល បុគ្គលិកជាន់ខ្ពស់ ឬនិយោជិត។

២២-ករណីអាជ្ញាបណ្ណធុរកិច្ចសំខាន់ណាមួយត្រូវបានព្យួរ ឬមានការសម្រេចចិត្តក្នុងការបញ្ឈប់សកម្មភាពធុរកិច្ចសំខាន់ណាមួយរបស់បុគ្គលបោះផ្សាយ។

២៣-ការព្យួរ ការបញ្ឈប់ ឬការចាប់ផ្តើមដំណើរការឡើងវិញនូវសកម្មភាពធុរកិច្ចណាមួយដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃការលក់សរុបរបស់បុគ្គលបោះផ្សាយសម្រាប់ឆ្នាំសារពើពន្ធចុងក្រោយសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃការលក់សរុបរបស់បុគ្គលបោះផ្សាយសម្រាប់ឆ្នាំសារពើពន្ធចុងក្រោយសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

២៤-ការបញ្ឈប់ប្រតិបត្តិការជាមួយអតិថិជនដែលទិញទំនិញ ឬសេវាដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃការលក់សរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃការលក់សរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

២៥-ការព្យួរមួយផ្នែក ឬទាំងស្រុងនៃធុរកិច្ចដែលមានផលប៉ះពាល់ចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃការលក់សរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃការលក់សរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុប ចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

២៦-ការសម្រេចចិត្តវិនិយោគ ដោយរួមទាំងការទិញលក់មូលបត្ររបស់ក្រុមហ៊ុនផ្សេងទៀត ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបរបស់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបរបស់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

២៧-ការសម្រេចចិត្តវិនិយោគលើបរិក្ខារថ្មី ការសម្រេចចិត្តពង្រីកបរិក្ខារដែលមានស្រាប់ ឬការសម្រេចចិត្តសាងសង់រោងចក្រថ្មី ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃ

ពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបសម្រាប់បុគ្គលបោះ-ផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

២៨- ការសម្រេចចិត្តបង្កើនកម្ចីរយៈពេលខ្លី ឬរយៈពេលវែង ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០(ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥(ប្រាំ) ភាគរយ ឡើងទៅនៃមូលធនភាគ-ហ៊ុនិកសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។ កម្ចីរយៈពេលខ្លីនេះរួមទាំងមូលបត្របំណុលដែលមានឥណប្រតិទានមិនលើសពី ០១ (មួយ) ឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្របោះផ្សាយផ្សេងពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

២៩- ការកើតមានឡើងនូវប្រធានសក្ដិដែលមានផលប៉ះពាល់ចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ២,៥ (ពីរក្បៀសប្រាំ) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣០- ការទិញ ឬការលក់ទ្រព្យសកម្មរូបី ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០(ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបសម្រាប់បុគ្គលបោះ-ផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០(ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣១- ការព្រមព្រៀងលើកិច្ចសន្យាណាមួយដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃទ្រព្យសកម្ម បំណុល សិទ្ធិ ផលប្រយោជន៍ ឬលទ្ធផលធុរកិច្ចរបស់បុគ្គលបោះផ្សាយ សម្រាប់បុគ្គលបោះ-ផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃទ្រព្យសកម្ម បំណុល សិទ្ធិ ផលប្រយោជន៍ ឬលទ្ធផលធុរកិច្ចរបស់បុគ្គលបោះផ្សាយ សម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣២- ការបាត់បង់តម្លៃនៃមូលធនភាគហ៊ុនិកសរុបច្រើនជាងពាក់កណ្ដាល នៃឆ្នាំសារពើពន្ធចុងក្រោយ។

៣៣- ការថយចុះ ឬការកើនឡើងនៃចំណូលរបស់បុគ្គលបោះផ្សាយដែលបណ្ដាលមកពីការលក់ ឬករណីមានចំណេញ/ខាតប្រតិបត្តិការ ឬចំណេញ/ខាតសុទ្ធ ធៀបទៅនឹងពេលដូចគ្នានៃឆ្នាំសារពើពន្ធ

ចុងក្រោយ ដែលថយចុះ ឬកើនឡើងចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅ សម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ ឡើងទៅ សម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣៤- ការកើតមានឡើងនូវឱនភាព ឬការខាតបង់លើសពី ១០ (ដប់) ភាគរយ នៃទ្រព្យសកម្មរបស់បុគ្គលបោះផ្សាយ។

៣៥- ការកើតមានឡើងនូវព្រឹត្តិការណ៍ណាមួយដែលបណ្តាលឱ្យបុគ្គលបោះផ្សាយ មិនមានលទ្ធភាពសងបំណុលដូចមានចែងក្នុងចំណុចទី ២៨ នៃប្រការនេះ។

៣៦- ការសម្រេចចិត្តក្នុងការប្រមូលមកវិញ ឬកម្ទេចចោល ផលិតផលរបស់បុគ្គលបោះផ្សាយ។

៣៧- ករណីបុគ្គលបោះផ្សាយទទួលរងទណ្ឌកម្ម ឬការផាកពិន័យ ដែលមានចំនួនទឹកប្រាក់ចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឬចាប់ពី ០៥ (ប្រាំ) ភាគរយ ឡើងទៅនៃមូលធនភាគហ៊ុនិកសរុបសម្រាប់បុគ្គលបោះផ្សាយដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣៨- ករណីដែលយោបល់របស់សវនករឯករាជ្យ លើរបាយការណ៍ហិរញ្ញវត្ថុរបស់បុគ្គលបោះផ្សាយ ជាទស្សនៈដែលមានបញ្ហា (Qualified Opinion) ជាទស្សនៈនៃការប្រឆាំង (Adverse Opinion) ឬជាទស្សនៈនៃការបដិសេធមិនទទួលខុសត្រូវ (Disclaimer of Opinion)។

៣៩- ករណីដែលមានព្រឹត្តិការណ៍ ឬហេតុការណ៍អាចប៉ះពាល់ដល់ថ្លៃ ឬការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ។

៤០- ករណីផ្សេងទៀតដែលអគ្គនាយកនៃ **គ.ម.ក.** យល់ថាចាំបាច់ ហើយដែលអាចមានផលប៉ះពាល់លើការសម្រេចចិត្តវិនិយោគរបស់វិនិយោគិន។

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ភ្លាម ប្រសិនបើព្រឹត្តិការណ៍ណាមួយ ដូចបានរៀបរាប់ក្នុងកថាខណ្ឌទី ១ ខាងលើ បានកើតឡើងក្នុងរយៈពេលមួយម៉ោងមុនម៉ោងជួញដូរ ឬក្នុងម៉ោងជួញដូរ។

ករណីព្រឹត្តិការណ៍បានកើតឡើងនៅក្រៅម៉ោងជួញដូរ តែក្នុងម៉ោងធ្វើការ បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ក្នុងម៉ោងធ្វើការនៃថ្ងៃដែលព្រឹត្តិការណ៍នោះបានកើតឡើង។

ករណីព្រឹត្តិការណ៍បានកើតឡើងខុសពីការចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ឱ្យបានមួយម៉ោងមុនម៉ោងជួញដូរនៅថ្ងៃបន្ទាប់។

## ប្រការ ៦.- របាយការណ៍សាមាយិកដែលត្រូវបង្ហាញ

បុគ្គលបោះផ្សាយ ត្រូវផ្ដល់របាយការណ៍សាមាយិកជូន **គ.ម.ក.** រួមមាន របាយការណ៍ប្រចាំឆ្នាំ របាយការណ៍ប្រចាំឆមាស និងរបាយការណ៍ប្រចាំត្រីមាស។

អគ្គនាយកនៃ **គ.ម.ក.** អាចស្នើសុំឱ្យបុគ្គលបោះផ្សាយ ផ្ដល់នូវរបាយការណ៍ស្ដីពីលទ្ធផលហិរញ្ញវត្ថុប្រចាំឆ្នាំ និងប្រចាំឆមាសមុនធ្វើសវនកម្ម។

រាល់របាយការណ៍ដែលដាក់ជូន **គ.ម.ក.** ដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវមានចុះកាលបរិច្ឆេទច្បាស់លាស់ និងមានហត្ថលេខារបស់អភិបាលទាំងអស់ ដោយមាននិទ្ទេសថា "***បានអាន និងឯកភាព***" ឬហត្ថលេខារបស់តំណាងអភិបាលដែលទទួលបានការផ្ទេរសិទ្ធិ ក្នុងការចុះហត្ថលេខាជំនួស ដោយត្រូវមានភ្ជាប់នូវលិខិតផ្ទេរសិទ្ធិ។

## ប្រការ ៧.- របាយការណ៍ប្រចាំឆ្នាំ

បុគ្គលបោះផ្សាយ ត្រូវផ្ដល់របាយការណ៍ប្រចាំឆ្នាំជូន **គ.ម.ក.** ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ**គ.ម.ក.**។ ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ រួមមាន÷

១- ព័ត៌មានទូទៅរបស់បុគ្គលបោះផ្សាយ។

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក។

៣- អភិបាលកិច្ចសាជីវកម្ម។

៤- សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលបោះផ្សាយ។

៥- របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

៦- របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង។

៧- ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ។

៨- ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

៩- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង។

១០- បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់។

១១- ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលរបស់បុគ្គលបោះផ្សាយ។

១២- ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន។

## ប្រការ ៨.- របាយការណ៍ប្រចាំឆមាស

បុគ្គលបោះផ្សាយ ត្រូវផ្ដល់របាយការណ៍ប្រចាំឆមាសជូន **គ.ម.ក.** ក្នុងអំឡុងពេល ៤៥ (សែសិប

ប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ចប់ឆមាសនៃឆ្នាំសារពើពន្ធ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំឆមាស រួមមាន÷

១- ព័ត៌មានទូទៅរបស់បុគ្គលបោះផ្សាយ។

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក។

៣- អភិបាលកិច្ចសាជីវកម្ម។

៤- សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលបោះផ្សាយ។

៥- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

៦- សេចក្តីថ្លែងរបស់សវនករឯករាជ្យ ថាតើបានដឹងថាមានបញ្ហាណាមួយដែលកើតឡើងក្នុងអំឡុងពេលពិនិត្យឡើងវិញ ហើយមានឥទ្ធិពលលើរបាយការណ៍ហិរញ្ញវត្ថុ។

៧- របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង។

៨- ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ។

៩- ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

១០- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង។

១១- ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន។

**ប្រការ ៩.- របាយការណ៍ប្រចាំត្រីមាស**

បុគ្គលបោះផ្សាយ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាសជូន **គ.ម.ក.** ក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ចប់ត្រីមាសនៃឆ្នាំសារពើពន្ធ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំត្រីមាស រួមមាន÷

១- ព័ត៌មានទូទៅរបស់បុគ្គលបោះផ្សាយ។

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក។

៣- អភិបាលកិច្ចសាជីវកម្ម។

៤- សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលបោះផ្សាយ។

៥- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

៦- សេចក្តីថ្លែងរបស់សវនករឯករាជ្យ ថាតើបានដឹងថាមានបញ្ហាណាមួយដែលកើតឡើងក្នុងអំឡុងពេលពិនិត្យឡើងវិញ ហើយមានឥទ្ធិពលលើរបាយការណ៍ហិរញ្ញវត្ថុ។

៧- របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង។

៨-ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ។

៩-ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

១០-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង។

១១-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន។

**ប្រការ ១០.- ព័ត៌មានពិសេសដែលត្រូវបង្ហាញ**

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានពិសេសជូន **គ.ម.ក.** ដែលរួមមាន ព័ត៌មានពាក់ព័ន្ធនឹងការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ (Stock Buy-Back and Cancellation) សំណើទិញផែនដី (Tender Offer) ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក (Merger and Acquisition) និងការទទួលកាន់កាប់បន្ត (Takeover)។

**ប្រការ ១១.- ការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ**

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ក្នុងអំឡុងពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការទិញមកវិញនិងការលុបចោលនូវមូលបត្រកម្មសិទ្ធិ ដូចខាងក្រោម÷

១-ការសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការទិញមកវិញ។

២-ព័ត៌មានអំពីបុគ្គលបោះផ្សាយ។

៣-គោលបំណងនៃការទិញមកវិញ។

៤-ព័ត៌មានលម្អិតអំពីការទិញមកវិញ។

៥-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១២.- ការផ្តល់នូវរបាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ**

បុគ្គលបោះផ្សាយ ត្រូវផ្តល់របាយការណ៍ស្តីពីលទ្ធផលពីការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិ ជូន **គ.ម.ក.** ក្នុងអំឡុងពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីប្រតិបត្តិការនៃការទិញមកវិញ និងលុបចោលបានសម្រេច។

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានភ្លាមជូន **គ.ម.ក.** នៅពេលដែលប្រតិបត្តិការនៃការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិ មិនបានសម្រេច ឬមិនទាន់បានសម្រេច តាមរយៈពេលដែលបានកំណត់។

### ប្រការ ១៣.- ការមិនអនុញ្ញាតលើការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ

ការទិញមកវិញនិងការលុបចោលមូលបត្រកម្មសិទ្ធិ ត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។ ការទិញមកវិញនិងលុបចោលមូលបត្រកម្មសិទ្ធិ មិនត្រូវបានអនុញ្ញាតឡើយ ប្រសិនបើការទិញមកវិញនិងការលុបចោលនោះខុសពីព័ត៌មានដែលបានផ្តល់ក្នុងឯកសារទិញនិងលុបចោលដែលបានដាក់ជូន **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ១៤.- សំណើទិញផែនឌ័រ

បុគ្គលដែលមានបំណងធ្វើសំណើទិញផែនឌ័រ ត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ក្នុងអំឡុងពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងការធ្វើសំណើនេះ ដូចខាងក្រោម÷

១-ព័ត៌មានអំពីបុគ្គលធ្វើសំណើទិញផែនឌ័រ។

២-ព័ត៌មានអំពីបុគ្គលគោលដៅ។

៣-គោលបំណងនៃការធ្វើសំណើទិញផែនឌ័រ។

៤-ប្រភេទ ចំណាត់ថ្នាក់ និងចំនួនមូលបត្រកម្មសិទ្ធិដែលជាកម្មវត្ថុនៃសំណើទិញផែនឌ័រ។

៥-វិធីសាស្ត្រនៃសំណើទិញផែនឌ័រ ដូចជាវិធីសាស្ត្រនៃការធ្វើបរិវិសកម្ម និងវិធីសាស្ត្រនៃការលុបចោលសំណើទិញផែនឌ័រ។

៦-លក្ខខណ្ឌនៃសំណើទិញផែនឌ័រ ដូចជា រយៈពេល ថ្លៃ កាលបរិច្ឆេទទូទាត់ និងវិធីសាស្ត្រទូទាត់។

៧-ប្រភពមូលនិធិចាំបាច់សម្រាប់ការធ្វើសំណើទិញផែនឌ័រ។

៨-ការតែងតាំងក្រុមហ៊ុនមូលបត្រឱ្យធ្វើជាភ្នាក់ងារក្នុងការធ្វើសំណើទិញផែនឌ័រ។

៩-ព័ត៌មានផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

ការធ្វើសំណើទិញផែនឌ័រ ត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ១៥.- ការហាមឃាត់លើសំណើទិញផែនឌ័រ

លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យធ្វើសំណើទិញផែនឌ័រ មិនត្រូវ÷

១-ដកសំណើសុំទិញទេ លុះត្រាតែមានព្រឹត្តិការណ៍ប្រធានសក្តិ ឬមហន្តរាយដែលមិនអាចព្យាករណ៍ទុកជាមុនបាន និងបង្កឱ្យមានការខូចខាតចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបរបស់បុគ្គលដែលបានធ្វើសំណើ។

២-កែប្រែលក្ខខណ្ឌណាមួយនៃសំណើទិញផែនឌ័រ ដែលបានដាក់ជូន **គ.ម.ក.**។

៣-ទិញ ឬលក់ ខុសពីលក្ខខណ្ឌដែលចែងក្នុងឯកសារនៃសំណើទិញផែនឌ័រ ដែលបានដាក់ជូន **គ.ម.ក.**។

**ប្រការ ១៦.- ការទទួលកាន់កាប់បន្ត**

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មាន និងផ្តល់ឯកសារភ្ជាប់ពាក់ព័ន្ធជូន **គ.ម.ក.** ភ្លាម បន្ទាប់ពីមានការសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការទទួលកាន់កាប់បន្តធុរកិច្ចដទៃទៀត ទោះតាមរយៈការទិញយកមូលបត្រកម្មសិទ្ធិ ឬការទិញយក ឬការផ្ទេរទ្រព្យសកម្មស្នូលរបស់ក្រុមហ៊ុនគោលដៅ ដូចខាងក្រោម÷

១-ពិពណ៌នាអំពីគោលបំណងនៃការទទួលកាន់កាប់បន្ត។

២-ពិពណ៌នាពីក្រុមហ៊ុនគោលដៅដែលជាកម្មវត្ថុនៃការទទួលកាន់កាប់បន្ត។

៣-ពិពណ៌នាលម្អិតអំពីប្រតិបត្តិការនៃការទទួលកាន់កាប់បន្ត។

៤-ព័ត៌មានផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

បុគ្គលបោះផ្សាយ អាចអនុវត្តការទទួលកាន់កាប់បន្តបាន បន្ទាប់ពីមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៧.- ការផ្តល់នូវរបាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការទទួលកាន់កាប់បន្ត**

បុគ្គលបោះផ្សាយ ត្រូវផ្តល់របាយការណ៍លទ្ធផលនៃការទទួលកាន់កាប់បន្តជូន **គ.ម.ក.** ក្នុងអំឡុងពេល ០៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានបញ្ចប់ការទទួលកាន់កាប់បន្ត។

ករណីការទទួលកាន់កាប់បន្ត មិនបានសម្រេច បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានភ្លាមជូន **គ.ម.ក.**។

**ប្រការ ១៨.- ករណីមិនចាត់ទុកជាការទទួលកាន់កាប់បន្ត**

ករណីមិនចាត់ទុកជាការទទួលកាន់កាប់បន្ត មានដូចខាងក្រោម÷

១-ការទិញ ឬលក់ផលិតផល វត្ថុធាតុដើម ការទិញស្តុកទុក ឬសន្និធិដទៃទៀត។

២-ការទិញ ឬលក់មូលបត្រកម្មសិទ្ធិដែលមានទំហំមិនលើសពី ៣០ (សាមសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុបរបស់ក្រុមហ៊ុនគោលដៅ។

៣-ការទិញ ឬការលក់ទ្រព្យសកម្មដោយសារដល់ខូចផ្លាស់ប្តូរ។

៤-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយករវាងផ្នែកនានារបស់ក្រុមហ៊ុនតែមួយ។

៥-សកម្មភាពផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៩.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក**

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មាន និងផ្តល់ឯកសារភ្ជាប់ពាក់ព័ន្ធជូន **គ.ម.ក.** ភ្លាម បន្ទាប់ពីមានការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក ដូចខាងក្រោម៖

១-ការពិពណ៌នាអំពីគោលបំណងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក។

២-ការពិពណ៌នាអំពីក្រុមហ៊ុនដែលជាកម្មវត្ថុនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក។

៣-ការពិពណ៌នាលម្អិតអំពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក។

៤-ព័ត៌មានផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

បុគ្គលបោះផ្សាយ អាចអនុវត្តការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក បន្ទាប់ពីមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ២០.- ការផ្តល់នូវរបាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក**

បុគ្គលបោះផ្សាយ ត្រូវផ្តល់របាយការណ៍លទ្ធផលពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក ជូន **គ.ម.ក.** ក្នុងអំឡុងពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានបញ្ចប់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក។

ករណីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក មិនបានសម្រេច បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានភ្លាមជូន **គ.ម.ក.**។

**ប្រការ ២១.- ព័ត៌មានតាមការស្នើសុំដែលត្រូវបង្ហាញ**

បុគ្គលបោះផ្សាយ ត្រូវផ្តល់ព័ត៌មានភ្លាម នៅពេលដែលមានការស្នើសុំពីអគ្គនាយកនៃ **គ.ម.ក.** ចំពោះករណីដូចខាងក្រោម៖

១-ពាក្យចចាមអារាម ដំណឹង ឬព័ត៌មាន ដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់បុគ្គលបោះផ្សាយ ឬថ្លៃមូលបត្ររបស់បុគ្គលបោះផ្សាយ។

២-ព័ត៌មានដែលអាចធ្វើឱ្យមានការប្រែប្រួលថ្លៃ និងទំហំជួញដូរមិនប្រក្រតីនៃមូលបត្រ។

៣-ព័ត៌មានដែលអាចមានផលប៉ះពាល់ចំពោះផលប្រយោជន៍វិនិយោគិន។

៤-ព័ត៌មានផ្សេងទៀតដែលស្នើសុំឡើងដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣

## នីតិវិធី និងយន្តការក្នុងការបង្ហាញព័ត៌មាន

**ប្រការ ២២.- ការតែងតាំងបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន**

បុគ្គលបោះផ្សាយ ត្រូវចាត់តាំងបុគ្គលិកយ៉ាងតិច ០១ (មួយ) រូប ដែលត្រូវបានចាត់ទុកថាជាបុគ្គលិកជាន់ខ្ពស់ និងមានគុណវុឌ្ឍិ ស្របតាមប្រការ ២៣ នៃប្រកាសនេះ ដើម្បីទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ហើយត្រូវបញ្ជូនឈ្មោះបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាននោះជូន **គ.ម.ក.** ក្រោយពេលត្រូវបានចាត់តាំង។ ករណីមានការផ្លាស់ប្តូរបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន បុគ្គលបោះផ្សាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជូន **គ.ម.ក.** ភ្លាម។ ករណីបុគ្គលបោះផ្សាយជ្រើសរើសបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មានថ្មីមិនទាន់បាន បុគ្គលបោះផ្សាយអាចតែងតាំងបុគ្គលិកជាន់ខ្ពស់ណាម្នាក់ឱ្យទទួលបន្ទុកក្នុងការផ្តល់ព័ត៌មានបណ្តោះអាសន្នបាន។

**ប្រការ ២៣.- គុណវុឌ្ឍិរបស់បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន**

បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតឧត្តមសិក្សា ហើយមានបទពិសោធន៍ការងារយ៉ាងតិច ០៣ (បី) ឆ្នាំ ពាក់ព័ន្ធនឹងជំនាញក្នុងការទំនាក់ទំនង និងត្រូវឆ្លងកាត់ការបណ្តុះបណ្តាលដែលរៀបចំដោយ **គ.ម.ក.**។

**ប្រការ ២៤.- ការទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន**

បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានសាជីវកម្មដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ។ បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ត្រូវរក្សាទំនាក់ទំនងដោយផ្ទាល់គ្រប់ពេលវេលាជាមួយនឹងមន្ត្រីទទួលបន្ទុកព័ត៌មានសាជីវកម្មនៃ **គ.ម.ក.**។

**ប្រការ ២៥.- មធ្យោបាយ និងបែបបទក្នុងការផ្តល់ព័ត៌មាន**

បុគ្គលបោះផ្សាយ ត្រូវរៀបចំព័ត៌មានសាជីវកម្មដែលត្រូវបង្ហាញដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវផ្តល់ជូន **គ.ម.ក.** ដោយផ្ទាល់តាមរយៈបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ឬតាមរយៈទូរសារ ឬសារអេឡិចត្រូនិច ឬមធ្យោបាយផ្សេងទៀតតាមការកំណត់របស់ **គ.ម.ក.**។

នៅលើឯកសារជាលាយលក្ខណ៍អក្សរ ដែលដាក់ជូន **គ.ម.ក.** បុគ្គលបោះផ្សាយ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី÷

- ឈ្មោះរបស់បុគ្គលបោះផ្សាយ។

- អក្សរកូដរបស់បុគ្គលបោះផ្សាយ។
- កាលបរិច្ឆេទ និងពេលវេលានៃការបញ្ជូន។
- ឈ្មោះបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន និងហត្ថលេខា។

ករណីបុគ្គលបោះផ្សាយមានបំណងផ្សព្វផ្សាយឯកសារដែលដាក់ជូន **គ.ម.ក.** ជាសាធារណៈ នោះនៅលើក្បាលទំព័រត្រូវមានសរសេរអក្សរថា **"សម្រាប់ផ្សព្វផ្សាយជាសាធារណៈ"**។

ករណីបុគ្គលបោះផ្សាយមានបំណងផ្តល់ឯកសារជូន **គ.ម.ក.** សម្រាប់តែការប្រើប្រាស់ផ្ទៃក្នុង នោះនៅលើក្បាលទំព័រត្រូវមានសរសេរអក្សរថា **"មិនសម្រាប់ផ្សព្វផ្សាយជាសាធារណៈ"**។

ចំពោះព័ត៌មានទាន់ពេល ឬក្នុងករណីបន្ទាន់ ការផ្តល់ព័ត៌មានសាជីវកម្មជូន **គ.ម.ក.** ស្របតាមប្រកាសនេះ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬតាមការណែនាំបន្ថែមរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ២៦.- ការបញ្ជូនព័ត៌មានទៅទីផ្សារមូលបត្រប្រតិស្រុត**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវពិនិត្យផ្ទៀងផ្ទាត់លើព័ត៌មានដែលទទួលបានពីបុគ្គលបោះផ្សាយ ស្របតាមប្រកាសនេះ មុននឹងសម្រេចបញ្ជូនទៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីធ្វើការផ្សព្វផ្សាយភ្លាមដល់វិនិ-យោគិន និងសាធារណជន។ ទីផ្សារមូលបត្រប្រតិស្រុត ត្រូវធ្វើការផ្សព្វផ្សាយ និងចែកចាយព័ត៌មានទៅដល់វិនិយោគិន និងសាធារណជនតាមរយៈមធ្យោបាយផ្សព្វផ្សាយ ឬបុគ្គលចែកចាយដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

**ប្រការ ២៧.- ការស្នើសុំការអនុញ្ញាតក្នុងការបង្ហាញព័ត៌មានដល់ទីផ្សារ និងសាធារណជន**

បុគ្គលបោះផ្សាយ អាចបង្ហាញព័ត៌មានដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ ឬព័ត៌មានដទៃផ្សេងទៀត ដល់ទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន តាមរយៈគេហទំព័ររបស់បុគ្គលបោះផ្សាយ និង/ឬ តាមរយៈសារព័ត៌មាននានា បន្ទាប់ពីទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៤

## ភាតព្វកិច្ចក្នុងការអនុវត្តការផ្តល់ព័ត៌មាន

**ប្រការ ២៨.- ភាតព្វកិច្ចរបស់បុគ្គលបោះផ្សាយក្នុងការអនុវត្តការផ្តល់ព័ត៌មាន**

បុគ្គលបោះផ្សាយ ត្រូវ÷

១-ធានាថាយន្តការនៃការផ្តល់ព័ត៌មានមានប្រសិទ្ធភាព និងនិរន្តរភាព។

២-ធានាថាព័ត៌មាន និងរបាយការណ៍ដែលផ្តល់ជូន **គ.ម.ក.** មានភាពត្រឹមត្រូវ ច្បាស់លាស់ និង

ពេញលេញ ព្រមទាំងទាន់ពេលវេលា ដោយមិនត្រូវមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស ឬខ្វះនូវព័ត៌មានសំខាន់ណាមួយ។

៣-ការពារ រក្សាទុករាល់ព័ត៌មានដែលត្រូវបង្ហាញដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ។

៤-អនុវត្តតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.** ដែលតម្រូវឱ្យផ្តល់ព័ត៌មានបន្ថែម។

៥-ធានាថាព័ត៌មាន និងរបាយការណ៍ដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ទោះក្នុងរូបភាពណាក៏ដោយ មុនពេលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

៦-មានក្រមសីលធម៌ និងវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានសាជីវកម្ម សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ព្រមទាំងបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន។

**ប្រការ ២៩.- ភារកិច្ចរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

អភិបាល និងបុគ្គលិកជាន់ខ្ពស់÷

១-ត្រូវរក្សាការសម្ងាត់របស់បុគ្គលបោះផ្សាយ ដោយមិនត្រូវធ្វើឱ្យលេចឮ ឬផ្សព្វផ្សាយព័ត៌មាន និងរបាយការណ៍ដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ មុនពេលព័ត៌មាន និងរបាយការណ៍នោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២-ត្រូវទទួលខុសត្រូវលើការផ្តល់ព័ត៌មានរបស់បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន។

៣-ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមក្រមសីលធម៌ និងវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានសាជីវកម្ម។

**ប្រការ ៣០.- ភារកិច្ចរបស់បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន**

បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន÷

១-ត្រូវរក្សាការសម្ងាត់របស់បុគ្គលបោះផ្សាយ ដោយមិនត្រូវធ្វើឱ្យលេចឮ ឬផ្សព្វផ្សាយព័ត៌មាន និងរបាយការណ៍ដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ មុនពេលព័ត៌មាន និងរបាយការណ៍នោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២-ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌ និងវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានសាជីវកម្ម ដែលអនុម័តដោយបុគ្គលបោះផ្សាយ។

៣-មិនត្រូវអនុវត្តនូវការងារណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ក្នុងការផ្តល់ព័ត៌មាន។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**ប្រការ ៣១.- វិធានការរដ្ឋបាល**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម ÷

១-ការព្រមាន ឬដាស់តឿន។

២-ការស្នើឱ្យដាក់អនុស្សារណៈ។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការព្យួរការជួញដូរលើមូលបត្ររបស់បុគ្គលបោះផ្សាយ។

៥-ការដាក់កំហិតលើការបោះផ្សាយមូលបត្រ។

៦-ការតម្រូវឱ្យដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ។

៧-ការចាត់នីតិវិធីតាមបទប្បញ្ញត្តិជាធរមាន ដើម្បីព្យួរជាបណ្ដោះអាសន្ន ឬបញ្ឈប់ការងាររបស់អភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលិកទទួលបន្ទុកក្នុងការផ្ដល់ព័ត៌មាន និងរបាយការណ៍។

៨-ការតម្រូវឱ្យបុគ្គលបោះផ្សាយ និង/ឬអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលិកទទួលបន្ទុកក្នុងការផ្ដល់ព័ត៌មាន និងរបាយការណ៍ ទទួលខុសត្រូវចំពោះការខូចខាតដែលបណ្ដាលមកពីការបំពានបទប្បញ្ញត្តិនៃប្រកាសនេះ។

៩-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើស។

**ប្រការ ៣២.- វិធានការដាក់ពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលល្មើសនឹងប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន)រៀល។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ៣៣.- ការចេញគោលការណ៍ណែនាំ និងទម្រង់ក្នុងការបង្ហាញព័ត៌មាន**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ និងទម្រង់ក្នុងការបង្ហាញព័ត៌មាន ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលបោះ-

ផ្សាយ ឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៣៤.- បជិវាននកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៥.- ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២

**គាត ឈន់**

**កន្លែងទទួល÷**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងយុត្តិធម៌
- -ធនាគារជាតិនៃកម្ពុជា
- -គណៈកម្មការមូលបត្រកម្ពុជា
- -គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ ៣៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ